# អំពាវនាវដល់គណបក្សនយោបាយឲ្យជម្រុញអ្នកគាំទ្ររបស់ខ្លួនពាក់មួកសុវត្ថិភាពនៅពេលហែរក្បួនឃោសនាបោះឆ្នោត

យោងតាមរបាយការណ៍ដែលផ្សព្វផ្សាយដោយក្រសួងសាធារណការ និងដឹកជញ្ជូនកាលពីពេលថ្មីៗនេះ បានឲ្យដឹងថាចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍នៅប្រទេសកម្ពុជា បានធ្លាក់ចុះចំនួន ២% នៅក្នុងឆមាសទីមួយនៃឆ្នាំ២០១៣ បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ពិតមែនតែវាហាក់ដូចជាការធ្លាក់ចុះបន្តិចបន្តួច ប៉ុន្តែសម្រាប់ប្រទេសដែលបានឃើញការស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍នៅលើដងផ្លូវកើនឡើងទ្វេរដង បើធៀបកាលពី៦ឆ្នាំមុន ហើយមានមនុស្សយ៉ាងតិច៥នាក់ បានស្លាប់បាត់បង់ជីវិតនៅលើផ្លូវជារៀងរាល់ថ្ងៃ ការធ្លាក់ចុះបែបនេះគឺជាសមិទ្ធិផលមួយគួរឲ្យកត់សំគាល់ដែលគួរអោយអបអរសាទរ!

អាស្រ័យហេតុនេះហើយ ពត៌មានថ្មីៗបានចុះផ្សាយពីយុទ្ធនាការឃោសនាបោះឆ្នោតនៅរាជធានីភ្នំពេញ ដែលចូលរួមហែរក្បួនដោយអ្នកធ្វើដំណើរតាមទោចក្រយានយន្ត ដែលពាក់មួក (កាតឹប) របស់គណបក្សនយោបាយជំនួសឲ្យមួកសុវត្ថិភាព ហើយជាការបំពានច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលពិតជាគួរឲព្រួយបារម្ភ និងខកចិត្តយ៉ាងខ្លាំង។ អ្នកថ្មើរជើង អ្នកបើកបរទោចក្រយានយន្ត និងអ្នកជិះកង់ មានចំនួនជាង៨០%នៃចំនួនអ្នកស្លាប់សរុបដោយគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជា។ ប៉ុន្តែការស្លាប់របស់ពួកគេ អាចការពារបាន។

ការពាក់មួកសុវត្ថិភាព ជាកាយវិការសាមញ្ញមួយដែលអាចកាត់បន្ថយហានិភ័យនៃការរងរបួសក្បាលដល់ទៅ ៦៩ភាគរយ និងការស្លាប់ដល់ទៅ ៤២ភាគរយ ពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង។ អ្នករួមដំណើរតាមទោចក្រយានយន្ត គិតទាំងកុមារ ក៏ទទួលបានការការពារពីការពាក់មួកសុវត្ថិភាពដូចអ្នកបើកបរដែរពេលដែលទទួលរងនូវគ្រោះថ្នាក់ចរាចរណ៍។ តែជាអកុសល ពួកគេតិចជាង ១០ភាគរយប៉ុណ្ណោះបានពាក់មួកសុវត្ថិភាពនៅពេលធ្វើដំណើរនៅលើដងផ្លូវ។ យើងខ្ញុំសូមធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាលឲ្យពិនិត្យលទ្ធភាពពន្លឿនការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មីដែលក្នុងនោះក៏បានកំណត់ពីការពាក់មួកសុវត្ថិសម្រាប់អ្នកធ្វើដំណើរតាមទោចក្រយានយន្តទាំងអស់ (ទាំងអ្នកបើកបរ និងអ្នករួមដំណើរជាមួយ)។

ទោះបីជាយ៉ាងណាក៏ដោយក្នុងអំឡុងពេលពីរ ឬបីសប្តាហ៍ខាងមុខនេះ វាពិតជាមានភាពចាំបាច់សម្រាប់គ្រប់គណបក្សនយោបាយនានា ក្នុងការទទួចដល់អ្នកគាំទ្ររបស់ពួកគេទាំងអស់ឲ្យពាក់មួកសុវត្ថិភាពពេលធ្វើការហែរក្បួនឃោសនាការបោះឆ្នោត និងក្នុងការធ្វើដំណើរប្រចាំថ្ងៃរបស់ពួកេគ។ សូមបន្តសង្គ្រោះជីវិតមនុស្សនៅលើដងផ្លូវក្នុងព្រះរាជាណាចក្រកម្ពុជាដោយធ្វើយ៉ាងណាឲ្យអ្នកបោះឆ្នោតរបស់យើងមានសុវត្ថិភាពជាមុនសិន។

គឹម បញ្ញា
នាយកប្រចាំព្រះរាជាណាចក្រកម្ពុជា
អង្គការមូលនិធិបង្ការរបួស អាស៊ី